# សម្ភាសរបស់ឈ្មោះ មូង ទៀង

កៈ អ្នកសម្ភាសឈ្មោះ : ហោង សុជីវី ខៈ អ្នកត្រូវបានគេសម្ភាសឈ្មោះមូង ទៀង

## ពត៌មានសង្ខេបឈ្មោះ មូង ទៀង

*គាត់មានឈ្មោះថា មូង ទៀង ភេទស្រី អាយុ៧៣ឆ្នាំ គាត់កើតឆ្នាំជូត ទីលំនៅដ្ឋាននៅអូស្វាយ រោងក្របី អីក្របី ទីលំនៅបច្ចុប្បន្ននៅស្ទឹងត្រង់ ខេត្តកំពង់ចាម ។ កាលពីក្មេងគាត់ដើរស៊ីឈ្នួលគេ មិនបានចូលសាលារៀនទេ ។ ឪពុកលោកយាយស្លាប់តាំងពីគាត់អាយុ៤ខែដោយសារមានជំងឺ មើលមិនជា ហើយម្ដាយគាត់វិញ ត្រូវបានប៉ុលពតយកទៅសម្លាប់ ពេលជំនាន់ប៉ុលពត។ គាត់ជាកូនទី៣នៃគ្រួសារ បងប្អូនរបស់គាត់បានស្លាប់នៅសម័យប៉ុលពតអស់ហើយ រហូតមកដល់សព្វថ្ងៃ នៅសល់តែគាត់នៅម្នាក់ឯង។ គាត់បានរៀបការមានកូន៥នាក់ ប៉ុន្តែប្ដីរបស់គាត់ធ្វើទាហាន ត្រូវបានប៉ុលពតយកទៅសម្លាប់តាំងពីឆ្នាំ៧៥ គាត់ជាស្រីម៉េម៉ាយ ដើរស៊ីឈ្នួលគេ ដើម្បីចិញ្ចឹមកូន៥នាក់ ។រហូតដល់បច្ចុប្បន្ន កូនគាត់មានមុខរបររៀងៗខ្លួន ប៉ុន្តែមិនដែលគិតគូមើលថែគាត់ឡើយ។*

ខៈធម៌...

កៈចាស ជាដំបូងជម្រាបសួរលោកយាយ! ដំបូង ជម្រាបសួរលោកយាយ...!

ខៈចាស ចាស លើកដៃថ្វាយព្រះ...ចាស!

កៈចាស ថ្ងៃនេះ ចៅមានឱកាសមក សម្ភាសលោកយាយ ហើយថ្ងៃសម្ភាស គឺជាថ្ងៃទី២៤ខែ៩ ឆ្នាំ២០១៨ ហើយចៅ! មានឈ្មោះថាហោង សុជីវី ជាអ្នកសម្ភាសផ្ទាល់តែម្ដង ។

ចាស! ហើយលោកយាយឈ្មោះអីដែរ?

ខៈឈ្មោះទៀង

កៈ ហើយនាមត្រកូនលលោកយាយត្រូវ ជាមួយអត្តសញ្ញាណប័ណ្ណហ្នឹង! លោកយាយឈ្មោះអីដែរ?

ខៈខ្ញុំអត់ទាន់យកម៉ោ ផង!

កៈហើយលោកយាយចាំអ្ហេ ឈ្មោះអីដែរ ទាំងនាមប័ណ្ណ ត្រូវទាំងត្រកូលលោកយាយម៉ង?

ខ៖នាមត្រកូលខ្ញុំអូ? ជីតាខ្ញុំឈ្មោះមួង! មួង ទៀង។

ក៖ចាស

ខ៖ចាស កសិករក្រ! ណាស់ចៅអើយ...

ក៖អូ...

ខ៖មិនចង់យាយអីទេ ខ្ញុំ! ។

ក៖ហើយលោកយាយមានឈ្មោះហៅក្រៅ ផ្សេងពីហ្នឹងអ្នាអត់?

ខ៖អត់ទេ! អត់មានហៅអ្ហេ។

ក៖ហើយលោកយាយចឹង! លោកយាយ អាយុម៉ានហើយឆ្នាំហ្នឹង?

ខ៖អាយុ៧៣
(សំលេងកាត់៖កូនរត់ ទឹកភ្នែកហើយ)

ក៖លោកយាយ! ហើយចឹង លោកយាយ កើតឆ្នាំណាដែរ?

ខ៖ហ៊ឺ...ភ្លេចហើយ នាងណា! ភ្លេចឈឹង! ភ្លេចបាត់ហើយកូនអើយ...ប៉ុនចាំតែឆ្នាំ! ឆ្នាំជូត។ ចាស! ឆ្នាំជូត ជីដូន

(បងស្រីយាយ៖៨០! ៨៣អ្ហេ?)

ខ៖ចាស អត់ៗទាន់ដល់៨០អ្ហេ បងហ្អី! អត់ទាន់៨០អ្ហេ

(បងស្រីយាយ៖ដល់ហើយ!)

ខ៖ដល់ហើយ?

(បងស្រីយាយ៖ ហ្នឹងហើយ ដល់ហើយ ឆ្នាំជូតហ្នឹងអ្នា)

ខ៖អូ...ហ្នឹងហើយ ចឹងៗហើយ!

(បងស្រីយាយ៖ហ្នឹងហើយ)

ខ៖អូនអ្ហើយ ខ្ញុំវង្វេងវង្វាន់អស់ហើយខ្ញុំនុះ...

ក៖ហ៊ឹម!

ខ៖មានកូនប្រុស៥នាក់! មានប្រពន្ធ នឹកកូនទៅ ទៅលេងកូន ដល់ទៅលេងកូន ទៅៗណាក៏ទៅៗ មិនបាច់ម៉ោរ៉េ...! ហើយខ្ញុំវិលអស់ហើយខួរក្បាលខ្លាំង រត់ម៉ោនៅកូនរាល

ថ្ងៃហ្នឹង គ្នាក្រ! ផ្ទះកាំជណ្ដើរបីទេ ប៉ុនប្រពន្ធគាត់ចិត្តបាន ចិត្តបាន
បានតែខ្ញុំថាអត់ចង់យាយទេ កូនអ្អើយ...ពិបាកម្ល៉ោខ្ញុំ ពិបាកមែនទែន ក្រ! មហាក្រ...រាល់ថ្ងៃ
គ្មានអីទេ កូនអ្អើយ!

កៈដោយសារជីវិតបស់មនុស្សម្នាក់ៗ វាសនាខុសៗគ្នាអ្នា!

ខៈចាស វាគ្មានអាណាចេះតែរាប់វា ចាស់! ចេះតែរាប់វាទៅ កូនក៏គ្មានដីស្រែ ផ្ទះក៏គ្មាននៅ
នៅកាំជណ្ដើរបី អាលាយ ដេញ...អានាបក៏រក រកមិនឃើញទេអូនអើយ...ក្រ!
បើមិនជឿសួរយាយនោះចុះ! ហើយថាខ្ញុំចេះតែយាយ អ្ហេ! អត់ទេ ក្រមែនទែន
ក្រណាស់គ្មានទេ អត់មានប្ដី មានសីអីទេ មានតែកូនប្រុស៥នាក់ ដូចអ្ហី
យាយប្រាប់កូនឯងចឹង អត់ដែរអ្ហី...ម៉ែយកម៉ាមឿនអី រីក៏៥០០០អី ១០០០ទិញចាណី អត់!
អត់ទាល់តែសោះ ប៉ុនផ្ទះគេ គួរសម រួចម៉ោ អាចិត្តល្អ អាចិត្តបាន ម៉ោ! អាក្ររហាមហ្នឹង
អាកាំជណ្ដើរបី ផ្ទះចង់អាលំ ផ្ទះទឹកលិចស្មើផ្លូវហ្នឹង ចង់ដួល! ខ្ញុំរត់ដេក...ផ្ទះគេ ផ្ទះឯងទៅ
កូនអើយ...វេទនាណាស់ខ្ញុំ រាល់ថ្ងៃអ្នា! ហើយបានជីដូនហៅអោយម៉ោ ជួយបោស
ជួយលាងអីទៅ គ្រាន់បើម៉ាកាក់ម៉ាសេនអីទៅ ទិញអី ទិញអីហូបទៅកូន រួចម៉ោនេះ
ញាតិគេអោយលុយទៀត អ្នកជិតខាង គេអោយម្នាក់ម៉ាមឿន ម្នាក់ម៉ាមឿនហ្នឹង
បាន៣!៤មឿនហ្នឹង ជិះម៉ោល្មម...ក្រ!គ្មានណា ក្រដូចខ្ញុំទេ...។

កៈលោកយាយ នៅណាដែរលោកយាយ?

ខៈអ៊ូ...ខ្ញុំសព្វថ្ងៃ គ្មានអ្នកណាក្រដូចខ្ញុំទេ យាយ! ត្រឹមនៅមួយកូនចុះ នៅអ្ហី...អូស្វាយ
រោងកាបី ថារដ្ឋគេធ្វើផ្ទះអស់ រួចទៅ គេអត់ឃើញ អីក៏អត់ឃើញ
ចេះតែនាំម៉ែកូននៅអ្អើយកូនអ្អើយ...

កៈហើយយាយសព្វថ្ងៃ យាយនៅណា?

ខៈនៅអូក្របីហ្នឹង ! ស្រុកកំណើត...

កៈស្រុកកំណើតលោកយាយហ្នឹង?

ខៈស្រុកកំណើត ខ្ញុំឆ្ងាយណាស់!ស្រុកកំណើត ស្ទឹងត្រង់អូ! ស្ទឹងត្រង់ ខេត្តកំពង់ចាម

កៈហើយចឹងលោកយាយ ស្រុកកំណើតយាយ កាលពីមុនមកដល់អាលូវហ្នឹង យាយ!
ផ្លាស់ទីលំនៅ រយៈពេលម៉ានដែរ លោកយាយមានចាំអ្ហេ?

ខៈ៨ឆ្នាំហើយ

កៈលោកយាយមកនៅនេះ ធ្វើអីដែរលោកយាយ?

ខះអ្ហឺ...ខ្ញុំទឹមតែម៉ោ ព្រឹកមិញទេ កូនអ្ហើយ...ម៉ោជួយលាងចាន លាងអីលោក! បោសតែសំរាប់ បោសអីលោកចឹងទៅ ទឹមតែម៉ោព្រឹកមិញ ទឹមតែបោសរួចមិញហ្នឹង!

កះចាស ហើយលោកយាយ! ឪពុកម្ដាយលោកយាយឈ្មោះអីដែរទៅយាយ?

ខះអត់មានអ្ហេ ឪពុកម្ដាយងាប់ តាំងពីខ្ញុំ កើត! ម៉ោ តាម៉ូង!

កះចុះយាយអត់ចាំឈ្មោះគាត់ ហើយកាលហ្នឹង យាយអាយុម៉ាន?

ខះអាយុ៤ខែ!

កះអ្ហូ...ហើយយាយបានដំណឹង តាំងពីឪពុកម្ដាយយាយតាមរយះណាគេដែរចឹង?

ខះគាត់ឈឺ ងាប់...
កះហ៊ឹម! យាយអ្ហើយ!

ខះគាត់អត់អីទេ ប៉ុនគាត់ឈឺងាប់ រួចម្ដាយចិញ្ចឹមខ្ញុំ អាពតយកវៃចោលអស់ហើយ

កះលោកយាយអើយ ដូចថាជីវិតមានការតស៊ូ ជួបលំបាកអញ្ចឹង!
ហើយលោកយាយអ្ហឺ...មានជីវិតដែល ចាស់ជំនាន់មុន ពិបាកមែនទែន ហើយចៅ សូមជម្រាបសួរលោកយាយទៀត ទាក់ទងនឹងបងប្អូនលោកយាយមានម៉ាននាក់ដែរ?

ខះបងប្អូនក៏ងាប់ដែរ ប៉ុននៅតែមួយ! គេយកវៃចោលអស់ ជន្លៀសតាណ្ដោះ តាណ្ដោះ គេយកវៃចោល

កះលោកយាយកូនទីម៉ានលោកយាយ?

ខះខ្ញុំកូនទី៣ ។

កះអញ្ចឹង! សព្វថ្ងៃលោកយាយមានបងប្អូនម៉ាននាក់?

ខះអត់មានអ្ហេ ងាប់អស់ហើយ

កះចឹង?

ខះចាស

កះនៅសល់តែលោកយាយ?

ខះចាស នៅសល់តែខ្ញុំ នៅសល់ម្នាក់ឯង បានរត់រកកូន ។ កូនមានប្រពន្ធអីណា ចឹង! ចេះតែរត់រកកូន រត់ម៉ោ គេចិត្តមិនបានដូចយើង យ៉ាប់ណាស់កូនអ្ហើយ ស្រែកថាយ៉ាប់! គេមិនមករកយើងទេ ខ្លាចយើងស៊ី ទ្រព្យសម្បត្តិគេ ស៊ីអីទៅ នាំតែអស់លុយគេ

ក៖ចឹង?

ខ៖រួចអាកូនយើងប្រុសៗអ្នើយ វាខ្លាចប្រពន្ធវាទៀតហើយ ហើយខ្ញុំចេះតែតាណាត់តាណែង តាណាត់តាណែងចឹងទៅ!

ក៖លោកយាយហើយ អ្ហឺ...ហើយចុះលោកយាយ មានកូនម៉ាននាក់ដែរ?

ខ៖៥! ប្រុសទាំងអស់! មានប្រពន្ធទាំងអស់! ហ្នឹង! អា...៣ៅគេអ្នា ខ្ញុំមកនៅជាមួយ ។ ថា! ទៅវិញហើយ ថា! កុំទៅ នៅហ្នឹង ក្រ...រហេមរហាមម៉េច នៅហ្នឹងទៅ! បានកូនសិក្សា ។

ក៖កូនយាយ បង្កើតអ្ហឺ...នៅរៀន សិក្សាដល់កំរឹតណាដែរលោកយាយ?

ខ៖អត់មានទេកូន! កាលជំនាន់ហ្នឹង អត់មានរៀនអីទេ រៀនបានចេះ ម៉ាទិចៗ មានអីទេកូន! អត់មានចេះអីទេ ល្ងង់ទាំងអស់

ក៖យាយអត់អោយកូនទៅរៀនទេ អញ្ចឹងលោកយាយ?

ខ៖រៀនធើអីកូន! ចុះអត់មានលុយអោយកូនទៅរៀន អត់មានទេកូន អ្ហឺ...ហើយចូលសាលាត្រូវបង់ រួចទៅរៀន បាន...គ្រាន់តែម៉ាមើលដាច់ មើលអី ហ្នឹងបាន! បើថាអោយជ្រៅជ្រះអត់បានទេកូន

ក៖ចាស ចឹងយាយ! កាលសម័យមុន យាយបានរៀនសូត្របាន ដល់កំរឹតណាដែរ?

ខ៖ខ្ញុំ! អត់សោះម៉ង! ដើរ...ដឹងក្ដីធំឡើង ដើរបានប៉ុនកូនគេមិញហ្នឹង ដើរស៊ីឈ្នួលគេទៅ ស៊ីឈ្នួលដកស្ទូងគេទៅ គ្មានបានរៀន បានសូត្រអីទេកូនអើយ...ណ្ណ! ប៉ុនៗអារត់លេងនុះ វាគ្មានបានអីទេខ្ញុំអូ ប្រាប់ត្រង់ចឹងម៉ង ខ្ញុំគ្មានបានចេះអីម៉ាទិច...យើងអត់ម៉ែអត់ឪ ចេះតែដើរស៊ីឈ្នួលគេចឹងទៅ បើសព្វថ្ងៃហ្នឹង ស៊ីឈ្នួលគេខ្លះដែរ ប៉ុននៅជាមួយកូន កូនគេមិនអោយទៅ! នៅផ្ទះទៅ កូនស៊ីឈ្នួលរៀប ស៊ីម៉ង់នឹងគេខ្លះទៅ រួចនឹងភ្លំរួច មើលកូនអោយគេ គេទៅកំពង់សោមទៅ ធើសំណង់អោយចិន

ក៖ហ៊ឹម...! លោកយាយហើយអ្ហឺ...

ខ៖ប៉ាបាកណាស់កូនអើយ...

ក៖អញ្ចឹង! បំណងប្រាថ្នាលោកយាយ ថាចង់ធ្វើអីទៀតអត់យាយ?

ខ៖ហ៊ឹម...! មិនដឹងចង់ធើអីទៀតទេកូនអើយ...បើ ក្រយ៉ាងហ្នឹង! មិនដឹងចង់ធ្វើអី?

ក៖ហ៊ឹម...លោកយាយៗ កើតទាន់ប៉ុន្មានជំនាន់ដែរលោកយាយ?

ខ៖ ខ្ញុំកើតទាន់ជំនាន់អីទេ...ខ្ញុំភ្លេច! ខ្ញុំមិនដឹងជំនាន់អីទេ...ជំនាន់អី?ៗ អត់ចាំទេ...ខ្ញុំ!(សើច)

កៈលោកយាយ! ផ្ទះលោកយាយនៅកាលពីមុន ផ្ទះលោកយាយមានសភាពបែបណាដែរលោកយាយ កាលពីមុនអ្ហា?

ខៈមានសភាពចឹងអ្ហាកូន ខ្ទមអញ្ចឹងអ្ហាណារហូតមកដល់សព្វថ្ងៃ!

កៈហ៊ឹម!

ខៈមកនៅជាមួយកូនក៏ខ្ទម រួចខ្ញុំនៅ អីស្រុកកំណើត ស្ទឹងត្រង់ហ្នឹង អត់មានទេ អត់មានស្អីទេ លក់មើលខ្មោចប្ដីអស់

កៈហ៊ឹម!

ខៈអាលីង! ទាំងអស់តាម៉ង...! ប្ដីខ្ញុំងាប់៧៥ វៃដាច់ គាត់ធ្វើទាហាន ធ្វើទាហានវៃអាពត វៃអីអូ! ហើយគាត់ទៅ អ្ហឺ...រស់នៅអ្ហឺ...នៅផ្ទះ នៅក្រោមផ្ទះលោកហ៊ុន សែននៀក! គាត់ធ្វើទាហាន ការពារលោក! លោកតា លោកយាយហ្នឹង! អ្ហា អ្ហឺ...លោកអ្ហឺ លោកហ៊ុន សែនហ្នឹង! គាត់ម៉ោពេញឈ្មោះម៉ោ ប្ដីហ្នឹង! នៅយាមហ្នឹងម៉ោ ហើយគេវៃម៉េចត្រូវកាភ្លៅ...

កៈហ៊ឹម!

ខៈមើលៗទាល់តែអស់ អាលាយ!ខ្លួនក្រដើរ ដើរអញ្ចឹងតាម៉ងទៅ កូនអើយកូន...មិនអីទេ(ស្រែកយំ)

កៈចាស!

ខៈ ក្រៗមែនទែនអ្ហា ខ្ញុំ!

កៈយាយ! ដល់ពេលចឹង លោកតាស្លាប់ មូលហេតុអីកាលហ្នឹង?

ខៈគាត់ឈឺ!

កៈហើយកាលហ្នឹង លោកយាយគាត់ មានប្រាប់លោកយាយផ្ដែផ្ដាំអោយលោកយាយ ថាអោយកូនចៅ អ្ហាម៉េចម៉ាទេ?

ខៈកូនចៅហ្នឹង រកស៊ីចិញ្ចឹមខ្ញុំ! រួចកូនចៅ គេមិនចឹងអីណា គាត់ងាប់អាយុ ៥០គត់! ខ្ញុំ៣០...

កៈហ៊ឹម...

ខៈតាំងពីហ្នឹងម៉ោ!

កៈចាស ហើយកាលការ លោកយាយការអាយុម៉ាន?

ខៈការអាយុ១៦

ក៖អ៊ូ...នៅក្មេងដែរយាយ?

ខ៖ចាស

ក៖តែកាលហ្នឹង កាលហ្នឹងពេញៗរូបរាងហើយយាយណ្ណ?

ខ៖ចាស ពេញហើយ

ក៖អូ...កាលការហ្នឹង លោកយាយស្រលាញ់គ្នារឺក៏ឪពុកម្តាយជាអ្នករៀបចំអោយ?

ខ៖ ឪពុកម្តាយអោយ! ឪពុកម្តាយរៀបអោយ ឪពុកម្តាយចិញ្ចឹម ហើយអ្អឺ...អាល្ងវគាត់
ជំនាន់អាពតហ្នឹង យកវៃចោលគាត់ទាំងឡាន ទាំងឡានអស់ បើតាចិញ្ចឹមខ្ញុំមកនៅ
មានអីធូហើយនែ! តែតាចិញ្ចឹម គេយកវៃចោលអស់ហើយ

ក៖ហ៊ឹម...លោកយាយអ្អើយ!

ខ៖វេទនាណាស់កូនអើយ!

ក៖ចាស ហើយកាលហ្នឹង លោកយាយអ្អឺ...រៀបការហ្នឹង
លោកតាបង្គាប់ថ្លៃទឹកដោះដៃរអ្វាអត់?

ខ៖ជំនាន់ណុង! ដូចអត់មានអ្វេ គាត់បង្គាប់ផ្ទះ កាលហ្នឹង! បង្គាប់ផ្ទះចឹង
បានផ្ទះមួយខ្នងចឹងទៅ ការទៅ ហើយដល់ការរួចទៅ ម៉ែឪ អ្អឺ...រកស៊ីណ្ណោះណ្ណោះរកទៅ
នៅតែពីរនាក់ប្តីប្រពន្ធចឹងទៅ ក្រដូចតែគ្នា ប៉ុនតែវាបានធូធា! ដល់តែប្តីឈឺចឹងទៅ
ខ្ញុំលក់តាំងពីស្រែ តាំងពីផ្ទះ តាំងពីដីភូមិអីអស់ មើលប្តីរួចងាប់ម៉ង មើលអស់គាត់ងាប់!

ក៖ហើយផុតពីលោកតាទៅ លោកយាយរកស៊ីអីដើម្បីចិញ្ចឹមកូនចៅ កូនអ្អើយស៊ីឈ្នួលគេ
ស៊ីឈ្នួលដកស្ទូងគេ គេច្រូតគេទៅ យើងយកមកចិញ្ចឹមកូន ។ អញ្ចឹង! បានម៉ែទឹកភ្នែក
តាំងពីកំពស់ កំពង់នេះ ប្រាំនាក់! ខ្ញុំរកស៊ីចិញ្ចឹមទាំងអស់ គេគិតដែរថា អោយខ្ញុំយកប្តីទៅ
គេសាណុក គេអ្អឺ...ជួយចិញ្ចឹម ខ្ញុំថា! អត់ទេ សុខចិត្តធ្វើខ្ញុំគេ ចិញ្ចឹមកូនចុះ!
ដល់ទៅធំកាលោះ កាលោះអស់ទៅ គេរកលុយបានចឹង គេការប្រពន្ធខ្លួនគេទៅ ខ្លួនគេទៅ
គេអត់ស្គាល់យើងទេ ខ្លះទៅស្គាល់ ខ្លះទៅមិនស្គាល់!

ក៖អ្អឺ...យាយអញ្ចឹង! ដូចយាយកាលមុនឡើយចឹង!
លោកយាយបានឆ្លងកាត់ខ្សែរជីវិតច្រើន ហើយកាលពីជំនាន់ប៉ុលពតហ្នឹង
គេបានជន្លៀសលោកយាយ និងក្រុមគ្រួសារទៅណាដែរយាយ?

ខ៖អត់ទៅណាទេ នៅផ្ទះ! គេ...ប្រុងតែបញ្ជូនដាក់រណ្តៅដៃរហ្នឹង ប៉ុន្តែទាហានហ៊ុន
សែនចូលទាន់ ចូលទាន់ទៅ បាននៅរស្តៅ ពីរនាក់ប្តីប្រពន្ធ ទៅរួចទៅ

គេចូលធើទាហានធើអីជំនាន់ណុង ជំនាន់វែដាច់ហ្នឹងទៅ ដល់អ្នាចប់អាពត! គាត់ងាប់ប៉ាដោយ ចប់ហើយខ្ញុំ! ហើយបើគាត់ចប់ពីអាពតហ្នឹងប៉ាដោយខ្ញុំ តែគាត់ងាប់ទៅ រហេមរហាម ដើរស៊ីឈ្នួលគេចឹងទៅ គេចិញ្ចឹមកូន ចិញ្ចឹមអីចឹងទៅ គេរកលុយបាន គេការប្រពន្ធការអីទៅ គេមានស្គាល់យើងអីណា គេអត់ស្គាល់យើងអ្ហេ

កះហុឹម...អត់ស្គាល់លោកយាយ?

ខះថា...ប៉ាបាកណាស់កូន ទៅនៅជាមួយ អាបងអាទី១ គេយកទៅនៅ គេយកទៅនៅបានម៉ាន ៥!៥ថ្ងៃ វាថា ខ្ញុំហូប សាច់ជ្រូក! ទទួលទានសាច់ជ្រូក វាមិនកើត រួចខ្ញុំរកត្រី រួចគេស្តីអោយខ្ញុំថា សាច់ជ្រូកអីមិនកើតទេ ទៅៗរក អីណា ម្ហូបអីណាឆ្ងាញ់ទៅៗ មិនបាច់នៅលើផ្ទះខ្ញុំទេ។

កះហុឹម! ក៏ចុះម៉ោនៅជាមួយខ្ញុំទៅ គ្ររហាម! វាទៅយកខ្ញុំម៉ោ យប់!វាស្រែក ក្រណាស់ម៉ែអើយ វាមិនចេះនៅ ដល់រួច បាន៩!១០ថ្ងៃ វាម៉ោរួច វាយកទៅវិញ វាសុំអាប្អូនវាហ្នឹង ថាម៉ោសុំវាទៅវិញ មកនៅជាមួយហ្នឹង! បើថាវាមិនអោយទេ។ ខ្ញុំថា ខ្ញុំអត់ទៅ អានាប ពីរជំបរដេក ក៏ខ្ញុំនៅដែរ ខ្ញុំអត់ទៅវិញទេ ព្រោះកូនដេញហើយ អោយទៅវិញធើអី រួចកូនអ្ហើយ គេមានលុយទាំងដៃៗចឹងអ្នា ជាងមេសំណង់ចឹងអ្នា គេបើកម្តងម៉ាលានពីរលានចឹងអ្នាណា មិនថាអ្នា! ម៉ែយកម៉ាពាន់នែ ហើយ៥០០អ្ហេ? ទេ...!អត់ទេ គេអត់មើលមុខយើងផង បានថាខ្ញុំ ពល់ថ្ងៃព្រិលអស់ហើយកូនអ្ហើយ ចង់អីក៏ចង់ ចង់បានដែរ ប៉ុនខ្ញុំចេះតែទ្រាំទៅ តែយាយទៅចង់តែទឹកភ្នែកអ្ហេ ខ្ញុំ!។

កះហើយយាយ ដល់ពេលសម័យហ្នឹង តាំងពីប៉ុលពតអ្នាយាយ គេប្រើយាយធ្វើអីខ្លះ?

ខះវែកដី វែកដីផង ភ្ជួរអង្រៃ ដកស្ទូង អារណ្តៅដាក់ គេអោយភ្ជួរអោយជ្រៅៗ សំរាប់ដាក់យើងនៀក! រួចខ្ញុំវែក យើងវែកចឹងទៅ មិនទាន់ទេ គេស្តីអោយខ្ញុំចឹងទៅ ដល់ម៉ោងគេឈប់ បានគេអោយឈប់ បើមិនដល់ម៉ោង គេអត់អោយឈប់ទេ បបរចឹងដែរ គេវាល់អោយពីរម៉ានវែក រឺក៏២វែក គេកំណត់អោយប៉ុហ្នឹង!

កះ គេធ្លាប់ធ្វើបាបយាយអ្ហេ?

ខះអត់ទេ! អត់ដែលវៃ ដែលជេទេ គ្រាន់ថា មិត្តឯងធ្វើការអោយត្រឹមត្រូវតិច កុំខ្ជិលច្រអូសពេក រួចក្មេង កំពស់ៗនេះ បាន...ចៅខ្ញុំផង។

កះហុឹម! ហើយពេលហ្នឹងលោកយាយ បានពិសាបបរហ្នឹងប៉ុន្មានពេលម៉ាថ្ងៃ ?

ខះអ្ហឺ...ពីព្រឹក ថ្ងៃម៉ោង១១ គេអោយម៉ាពេល ម៉ោង៥ បានគេអោយម៉ាពេលទៀត ២ពេល!

ក៖ហើយឆ្អែតអ្ហេលោកយាយ?

ខ៖អូ...កូនអ្ហើយកូន ថាឆ្អែត យើងថាឆ្អែតទៅ មិនឆ្អែត ក៏យើងថាឆ្អែតទៅ ថា!មិនឆ្អែត គេស្តីអោយយើងទៀត សុំអំបិលគេម៉ាគ្រាប់! សុំ...បានសម្លហើយរកអំបិល! បើសម្ល អត់មានឃើញត្រីផង ឃើញតែដើមចេកទេកូន ថ្លាដូចទឹកអណ្តូងយើងចឹង ប៉ាហុកក៏មិនធុំ គ្មានត្រីអីអឺណាទេ ហើយសុំអំបិលគេម៉ោ គេថាមានសម្លហើយ រកអំបិលទៀត អើសអ្ហា! គេថាអោយអញ្ចឹងអ្ហា ចេះតែទ្រាំទៅ! ហុតទៅ គេស្តីអោយអ្ហាម៉េច ចេះតែទ្រាំៗទៅ ធើម៉េច! យើងក្រោមគេ

ក៖ហើយយាយកាលហ្នឹង ដូចជា...គេធ្វើបាបលោកយាយអ្ហេ ដូចថាដៃលវៃ ដៃលអីអត់?

ខ៖អត់ដែរទេ

ក៖អត់ដែរសោះម៉ង?

ខ៖អត់ដែរទេ! ចាស អត់ដែរទេ

ក៖ហើយលោកយាយ កាលហ្នឹង លោកយាយធ្លាប់ឈឺ
បើអត់សូវបានពិសាអត់គ្រប់អញ្ចឹង?

ខ៖ខ្ញុំអត់ដែរចឹង ខ្ញុំអត់ដែរឈឺ ទើសសព្វថ្ងៃហ្នឹង អត់ដែរឈឺ តាំងពីហ្នឹងម៉ោ ខ្ញុំអត់ដែរ។ អញ្ចឹងបានថា អ្នកស្រុកថា គេក្មេង អត់ដល់យាយហ្នឹងចាស់ អត់ដែរអ្ហេកូន! អត់ដែរឈឺទេ ខ្ញុំថាបើឈឺទៀត បែបងាប់ហើយខ្ញុំ គ្មានលុយមើលខ្លួន បើកូនក្រដែរ
ក៖ហើយសម័យកាលហ្នឹងដែរ លោកយាយអ្ហឺ...ដូចជាលោកយាយចងចាំទិដ្ឋភាពអីខ្លះ ដែលធ្វើអោយលោកយាយចងចាំអត់ភ្លេចសោះ នៅជំនាន់ប៉ុលពត?

ខ៖មិនភ្លេច តារឿងដកស្ទូង វែកដីហ្នឹងអ្ហា អត់ភ្លេច មិនភ្លេចទេ ចាំរហូត។

ក៖អញ្ចឹង?

ខ៖ចាស! ចាំបានតែអញ្ចឹង ព្រោះគេអត់ដែរវៃ អត់ដែរអីទេ! អត់ដែរវៃអត់ដៃលវៃយើងទេ អត់ដែរទេ! ប៉ុន្តែបើសិន គេប្រើ គេប្រើហើយ បើថាអោយគេវៃយើងអត់ទេ។ ប៉ុនសំដីធំ សំដីទូចក៏អត់ដែរ ប៉ុនថាគ្រាន់ថា មិត្តឯងធើការ កុំខ្ជិល! ធើទៅ វែកទៅ! ហាត់ម៉េច យើងហាត់ គេក៏ហាត់ដែរ មើលគេអត់ឈប់ យើងក៏អត់ឈប់ដែរ ដល់ម៉ោងឡើងម៉ង ឡើងមកដល់មុជទឹកទាន់ ទានមិនទាន់ហីទៅ ដល់វៃជួងម៉ើងចូលហើយ តែមិនចូលអត់។

ក៖ហ៊ឹម! យាយធ្លាប់ឃើញ ប៉ុលពត! គេយកមនុស្សទៅសម្លាប់ចោលនៅភ្នែកយាយអ្ហេ?

ខ៖ទេ...កូន! នឹងភ្នែកហ្នឹង អត់ឃើញទេ បើថាដាក់ឡានឃើញ...

កៈមានឡានដាក់ទៀត?

ខៈដាក់ឡាន ទម្លាក់ឃ្លុំបើតាម៉ង ជិត! ។ គ្រាន់តែម៉ែចិញ្ចឹមខ្ញុំ កូនគាត់១២នាក់! ម៉ែក្មេកគាត់ ពុកក្មេកគាត់ ប្អូនថ្លៃបងថ្លៃទៅទាំងអស់ អត់មាននៅ! រួចបើ...ឪពុកចិញ្ចឹមខ្ញុំ គេដាក់អណ្តូង គេឃ្លុំមុខដាក់អណ្តូងម៉ង

កៈហ៊ឹម...

ខៈអណ្តូងនៅលិចផ្ទាល់ភូមិហ្នឹងម៉ង

កៈលោកយាយឃើញផ្ទាល់ភ្នែកអ្ហេយាយ?

ខៈទេ...អាអណ្តូងហ្នឹងស្គាល់ ប៉ុន្តែមនុស្សអត់ស្គាល់ទេ ទៅ!គេ អ្នកលួចប្រាប់អ្ហា អាហ្នឹងគេយកវៃចោលបាត់ហើយ លួចប្រាប់តែតា...អ្ហឺ...ឪពុកថៅឯងដែរ គេដាក់ក្នុងហ្នឹង

កៈអញ្ចឹង! លោកយាយខ្លាច ?

ខៈខ្ញុំអត់ខ្លាចអ្ហេ អត់ខ្លាចផង អត់ខ្លាចទេ ខ្លាចខ្មោច ខ្លាចអីទេ អត់ចេះម៉ង...

កៈកាលហ្នឹង?...

ខៈខ្ញុំសួរហែង ឃើញអី អ្ហាហ៊ី...ពេញម៉ាអណ្តូងហ្នឹង មិនឃើញដីគេលុបអ្ហេ កាលហ្នឹង! គេដឹង គេយកបាញ់ចោលទៅ គេអត់ទុកទៀត នៅចោលប្រពន្ធកូនរហាម រាល់ថ្ងៃដូចខ្ញុំហ្នឹង ឃើញអ្ហេ?

កៈហើយកាលហ្នឹង លោកយាយមានធ្លាប់បន់ថា អោយឆាប់ដាច់ឆាប់ៗអ្ហេយាយ?

ខៈខ្ញុំអញ្ចេះ! ប្តីខ្ញុំម៉ោដល់ទន្លេហ្នឹង ដល់ឆ្លងម៉ោយើងអ្ហេ អីអ្ហឺ...កំពង់ទ្វាស់ អ្ហាអីអ្ហឺ...កំពង់ទ្វាស់ អីទេនៀក អី? ទន្លេបិទ! ខ្ញុំថា ទៅៗដល់ស្រុកយួនម៉ងទៅ បើមិនចឹងទេ វាតាមក្រោយហើយ តាមក្រោយមែន កំណើតអាពៅហ្នឹង កើតបានម៉ាអាទិត្យ បីកូនរត់ម៉ោ បានមកដល់ស្ទឹងត្រង់ហ្នឹង បានបន្ទាប់តា ហ៊ុន សែន ហើយបានគាត់ឡើងទាន់ ឡើងទាន់ បានគាត់ស្រែកថា អោយបកមកវិញ បកម៉ោ! បានមកនៅស្រុកវិញ

កៈចាស

ខៈចាស ដឹងតែប៉ុហ្នឹង ត្រង់ម៉ែឪគេយកទៅសម្លាប់ឃើញហើយអ្ហេ បើឡានឃើញប្រាកដ គាត់ប្រាប់ថា អោយឡើងឡានម៉ោ ទៅនៅដីថ្មី គេប្រាប់អញ្ចឹង!រួចម៉ែចិញ្ចឹមខ្ញុំហ្នឹង ខ្ញុំខំដាក់តាឡូង ដាក់ពោតដាក់! ស្អីអោយ...អ្ហឺ...ថាទៅនៅដីថ្មី មិនផ្គត់ផ្គង់អោយម្តាយដាំ មានដីថ្មីអីណា ដាក់ឃ្លុំបើអោយជិត មិនដឹងលិច មិនដឹងកើតផង អត់ដឹង រួចទៅបាត់ទៅ

រួចទៅលិចទៅ បាត់ទៅ! បើកឡានគេអញ្ចឹងទៅ រួចខ្ញុំសួរគេ
ហើយថាឡានហ្នឹងគេទៅដល់ណា ម៉េចសួរចង់ដឹង ចង់ទៅតាម?

ក៖ហ៊ឹម...

ខ៖ខ្ញុំហ្នឹង! ក៏លែងទៅ ចង់ទៅតាមអូ...? បើចង់ទៅតាមដាក់តែពីរគ្រាប់ទៅអ្នកនៀក

ក៖ហ៊ឹម...

ខ៖វាថា អោយខ្ញុំចឹងអ្នា! រួចក្មេងៗទេ

ក៖ហ៊ឹម!

ខ៖អញ្ចឹង?

ក៖យាយចឹង មានបងប្អូនអ្ហេ ស្លាប់ក្នុងសម័យប៉ុលពតអ្ហេ ?

ខ៖មាន! ទាំងអស់៧នាក់ សល់តែខ្ញុំមួយទេ!

ក៖ តែបងប្អូនផ្សេងទៀតក៏មានដែរ?

ខ៖មាន...!បងប្អូនខ្ញុំ ចិញ្ចឹមខ្ញុំច្រើន ម៉ែចិញ្ចឹមខ្ញុំ!១២នាក់ហ្នឹង

ក៖អញ្ចឹងយាយមានកូនទេ កាលសម័យប៉ុលពត?

ខ៖ខ្ញុំអ្ហេ?

ក៖ចាស មានកូនអ្ហេ ក្នុងសម័យប៉ុលពត?

ខ៖ខ្ញុំមានកូនតា

ក៖ក្នុងសម័យប៉ុលពតអ្នា?

ខ៖បី!

ក៖កាលហ្នឹងកូនអ្ហឺ...យាយ អាយុម៉ានដែរ?

ខ៖ខ្ញុំអាយុ៣០

ក៖កូនយាយអ្នា?

ខ៖កូនខ្ញុំ អាបងគេអ្នា អាយុ! បងគេបង្អស់១០ឆ្នាំ

ក៖ចាស!

ខ៖ចាស អាមួយ៨ ៨ឆ្នាំ! អាមួយ៧ខែ

ក៖តែអ្ហឺ...កូនយាយអត់មានស្លាប់ក្នុងជំនាន់ប៉ុលពតអ្ហេ លោកយាយអូ?

ខ៖អត់ទេ

ក៖អ្ហឺ...ហើយចុះ គេអោយយាយមើលកូន មើលថែរក្សាកូនខ្លួនឯងអ្ហាអត់?

ខ៖មាន...

ក៖គេអោយមើលអូ?

ខ៖ចាស! គេថា លាក់ៗខ្លួនខ្លះៗទៅ កុំសម្ដីលពេក ខ្លាចយួនម៉ោបាញ់ វាប្រាប់ខ្ញុំអញ្ចឹង! លាក់ៗខ្លួនទៅ រួចខ្ញុំថា លាក់ទៅខាងណា? បើខ្ញុំរកតែកំពតព្រៃអត់មានផងអ្ហ! វាថាលាក់ៗទៅប្រយ័ត្នយួនបាញ់ មិនដឹងអ្ហេ ងាប់មិនដឹងអ្ហេ ប៉ុនពួកវាហ្នឹងហើយបាញ់ មានយួនពីណា

សំលេងអ្នកក្រៅកាត់៖ ម៉ោពីណា? ម៉ោពីលោកតាស្រូចទឹក អូ...!លោកតាស្រូចទឹកអ្ហេ?)

អូ...ខ្ញុំថា មិនដឹងយួននៅណាអ្ហេ មិនឃើញយួនផង អញ្ចឹង! ខ្ញុំមិនដែលស្គាល់យួនអ្ហេ...រួចជំនាន់ហ្នឹងអ្ហឺ...ផ្ទះខ្ញុំវា នៅតូចដែរ...ប្តីខ្ញុំគាត់អត់នៅ យួនវាទៅនៅក្រោមផ្ទះហ្នឹង នៅក្រោមផ្ទះហ្នឹង ចងអង្រឹងចងអីចឹងទៅ អោយបានស៊ីទៅ វាអោយអីអោយយើងស៊ីទៅ អញ្ចឹងអ្ហាណា រួចវាប្រាប់យើងថា អោយចូលក្នុងរណ្ដៅទៅ ខ្លាចប្រទះគ្នា វៃគ្នាទៅ បាញ់គ្នាហើយ រួចប្តីខ្ញុំ គាត់ធ្វើទាហានដែរ ខ្ញុំនៅតែផ្ទះ! មានតែប្រាប់ បើ...គេមានបាញ់គ្នា កុំអោយគេចុះពីលើផ្ទះ ហើយបើប្តីខ្ញុំគាត់ទាហានដែរ ចុះខ្លាចអី? នៅជាមួយយួនទៀត បានខ្ញុំខ្លាច ប្តីខ្ញុំថា កុំចុះពីលើផ្ទះពួននៅក្រោមផ្ទះយើងហ្នឹង ប្រយ័ត្នវាបាញ់! ប៉ុនខ្ញុំអត់ដែលមានអីទេ រួចហើយអត់អីទេ ប៉ុន្តែអត់អីទេ...

ក៖ចុះលោកយាយ ជីវិតលោកយាយ តាំងពីមុនមករហូតដល់អាល្ងូវ មានការលំបាកអីគេខ្លះដែលធ្វើអោយយាយចងចាំ អត់ភ្លេចសោះម៉ង នៅក្នុងជីវិត?

ខ៖អ្ហើយចៅអើយ...ពិបាកមែនទែន ដូចខ្ញុំ ជម្រាបនាងថា ពិបាកមែនទែន រហូតដល់សព្វថ្ងៃហ្នឹងអ្ហា តាំងពីដើម រហូតមកទាល់អាល្ងូវហ្នឹងអ្ហា អត់ចេះបានពេលសាណុក ហើយក៏បានលុយកាន់ម៉ាមឿនអីហ្នឹង យកម៉ាពាន់ ប្រាំពាន់អីអោយច្បាស់ទេ អត់ទេ...អត់សោះឡើយ...រាល់ថ្ងៃហ្នឹង ។ ចុះបើកូនយើងក្រដែរហ្នឹង ទៅអ្ហឺ...ប៉េះក្រូចអីណាៗអី ស្អី អ្ហឺ...កំពង់សោមអីណានុះ កំពង់សោម! ខ្ញុំយកពីរនាក់ចៅ យកនែ...ចៅម៉ោអ្ហា

កៈហើយចាស! លោកយាយ រឿងដែលពិបាកជាងគេម៉ង ធ្វើអោយយាយនឹកចាំម៉ងអត់មានអ្ហេ?

ខៈអត់! មាន...

កៈមានច្រើនអ្ហេយាយ?ដូចថារឿងដែលធ្វើអោយនឹកចាំអត់ភ្លេចសោះម៉ោ តាំងពីឆ្នាំមុនរហូតដល់អាលូវអ្ហា មានៗច្រើនអ្ហេយាយ មានច្រើនអ្ហេ?

ខៈមានស្អី! មានតែក្រ...មីអូនអ្ហា អាយើងក្រវា ចេះតែក្រ...នៅជាមួយកូនវាមិនសុខណា អាកូនវាចេះតែថាអ្ហាណា យំអញ្ជឹងដែរណា យើងនៅម្នាក់ឯង យើងទៅស៊ីបាយទឹកវាមិនបានអ្ហាណា ម៉ែនឹកឃើញអាត្រង់ហ្នឹង បានម៉ែទឹកភ្នែកហ្នឹងអ្ហា វាដូចជាអត់សម កូនអស់នឹងគេ កូនគេ គេស្រលាញ់ម៉ែ...កូនខ្ញុំអត់ស្រលាញ់ទេ បានអ្ហាមួយឡាហាម! ដែលទៅកំពង់សោមបាត់ហ្នឹងអ្ហា ទៅស៊ីឈ្នួលគេ តែប៉ុហ្នឹង! ។ ខ្ញុំនៅតែចាំពាក្យខ្លួនខ្ញុំថា វាវេទនាអ្ហាណាកូន វេទនាមែនទែនអ្ហាណា។

កៈយាយចូលចិត្តអីដែរ ចូលចិត្តស្តាប់បទចម្រៀងអ្ហេ?

ខៈខ្ញុំសព្វថ្ងៃ ស្តាប់បទ! ចម្រៀងខ្លះទៅ ហើយជូនអី ស្តាប់តែលោកទេសន៍ បើ...កតែលោកទេសន៍ចឹងទៅ

កៈហើយមុខម្ហូប យាយចូលចិត្តមុខម្ហូបអីទៅ?

ខៈមុខម្ហូបកូនអើយចូលចិត្តជាងគេ ស្ងោទៅ ត្រសក់ទៅ ចំហុយប្រហុកទៅ សាច់ជ្រូកខ្ញុំមិនសូវអ្ហេ

កៈហើយកាលពីមុន លោកយាយចូលចិត្តលេងល្បែងអីគេដែរវីក៏ នៅកុមារភាពអ្ហា?

ខៈអ្ហឺអើយ...អត់ចេះទេ!

កៈ លេងល្បែងជានៅក្មេងៗអីចឹងអ្ហា...លេងល្បែងអីចឹងអ្ហា នៅក្មេងៗអីចឹងអ្ហា ចូលចិត្តលេងអី?

ខៈអត់ទេ...!អត់ដែរសោះ

កៈអត់ដែរសោះ?

ខៈចាស អត់ដែរៗ

កៈអត់ដែរៗ?

ខៈហ្នឹងហើយអត់ដែរសោះ!

កះលោកយាយ ដូចជារាល់ថ្ងៃ កាន់ព្រះពុទ្ធសាសនារាល់ថ្ងៃ?

ខះព្រះពុទសាសនា!

កះហើយរាល់ថ្ងៃ លោកយាយកាន់ព្រះពុទ្ធសាសនាដោយសារមូលហេតុអីដែរ?

ខះថា...ខ្ញុំសុំសិល៍ សុំអីហ្នឹង ថាអ្ហឺ...ទៅមុខទៀត ថា...កុំអោយអ្ហឺ...ពិបាកវេទនា កុំអោតរហេមរហាមអញ្ចឹង! ទឹកភ្នែកទឹកសំបោរអញ្ចឹង វាចេះតែស្តាប់ទៅ វាចេះតែសុំទៅ តាមគេតាមឯងទៅ ហើយសុំផឆ្នាំហើយ ចាស!

កះហើយលោកយាយគិតថា ព្រះពុទ្ធសាសនា ពេលលោកយាយជឿទៅ បានជាក់លាក់សំរាប់បុគ្គលអីខ្លះ សំរាប់អ្ហឺ...ផ្លូវកាយនិងផ្លូវចិត្ត?

ខះយើង! អ្ហឺ...វាស្រួលដែរហ្នឹង យើងជឿតាមព្រះពុទ្ធសាសនាទៅ ក៏ល្អម្យ៉ាងដែរ ខ្ញុំមិនដែលឈឺ មិនដែលអីដែរ មិនអីទេ ទៅសុំមានលុយមានកាក់ ទៅសុំសង្ហាន់ចឹងដែរទៅ ប្រាថ្នាជាតិក្រោយកុំអោយវាពិបាកវេទនា ដូចគ្នា!
កះលោកយាយកូនលោកយាយអី គាត់ជឿលើព្រះពុទ្ធសាសនាទាំងអស់គ្នាតាអ្ហាហី?

ខះកូនខ្ញុំ! ជឿទាំងអស់

កះចាស

ខះខែបុណ្យទានហ្នឹង គាត់ទៅវត្តហើយ បាយសម្ល! គាត់ទៅវត្តហើយ ទោះមានក្រអ្ហាម៉េច ក៏មានបាយម៉ាចាន សម្លម៉ាចានដែរ ហើយចៅ! ខ្ញុំមិនដែលចោលទេ។

កះ គាត់គោរពតាមប្រពៃណី តាមទំនៀមទំលាប់យើងម៉ោ?

ខះគាត់ជូនអី គាត់រាប់ទៅ ជូនអី គាត់ទៅៗ ។

កះហើយធ្វើបុណ្យអី ដែលគាត់តែងតែគោរពប្រនិបត្តិធ្វើជារាល់ឆ្នាំ?

ខះមិនដឹងធើបុណ្យអីទេ កូនអើយ...ភ្ជុំបិណ្ឌហ្នឹង ចេះតែធើទៅ ម៉ោអី ម៉ោវត្តទៅ ម៉ោលាង! សំអាតចាន សំអាតឆ្នាំង ហើយលាងចាន លាងឆ្នាំម៉ាព្រឹកហើយ បោសច្រាសនៅនឹងវត្តហ្នឹងទៅកូនអើយ ដឹងធើ...មិនដឹងធើអីទេ

កះចាស អ្ហឺ...សំរាប់ជីវិតលោកយាយផ្ទាល់ លោកយាយចង់បានអីទៀត នៅថ្ងៃអនាគត?

ខះថ្ងៃអនាគតចង់បានតែផ្ទះ បានល្អ...ស្រួល! ចង់នៅ ចង់ដេក អ្វៗហ្នឹង កូនអ្ហើយ! ថ្ងៃណាបាន បាននៅទៅ? បើកូនក្រយ៉ាងនេះ កូនរៀនផងអីផង សព្វថ្ងៃ! បានតែប្រាក់ បានតែស្អីគេ...? អីអ្ហាម៉េចគេទេ ខ្ញុំនៀក? ស្អីអ្ហា...? អាហារូបករណ៍អ្ហាម៉េចគេនោះ?

កៈចាស ចាស

ខៈក្មេងសិស្សសាលា រៀន! ហ្នឹង! ចូលភ្នំរួចហ្នឹង ចូលកងហើយ ឡើងថ្នាក់ទី៧!

កៈលោកយាយអញ្ចឹង! អ្វីដែលធ្វើអោយលោកយាយ
សប្បាយចិត្តជាងគេនៅក្នុងជីវិតលោកយាយ?

ខៈក្នុងជីវិតខ្ញុំអ្នកនាង! បើអោយខ្ញុំសប្បាយចិត្តគេមានផ្ទះសំបែងនៅ

(សំលេងកាត់ៈកូនមុំ...)

ខៈ ខ្ញុំអរហើយ!

(សំលេងកាត់ៈបិណ្ឌមួយស្អែក លោកកូន...)

កៈលោកយាយ ជាចុងក្រោយ លោកយាយមានពាក្យពេជន៍អី ដើម្បីផ្ដែផ្ដាំដល់កូនចៅ
ជំនាន់ក្រោយ?

ខៈ ម៉ាជំនាន់ក្រោយហ្នឹង កូនចៅជំនាន់ក្រោយហ្នឹង អោយដឹងៗ
ព្រះពុទ្ធសាសនាអោយដឹងម៉ែ ដឹងឪ ហ្នឹងហើយ! កុំអោយដូចខ្ញុំ ខ្ញុំ! កូនចៅ ខ្ញុំមិនដឹងទេ
កុំអោយកូនចៅក្រោយកុំអោយដូចខ្ញុំអញ្ចឹងទៀត អោយបានល្អ...ជាមួយម៉ែនឹងឪ
និងព្រះសង្ឃព្រះពុទ្ធព្រះធម៌ទៅ បានហើយ...។

កៈអរគុណលោកយាយ បើសិនជាសាលាគេចង់ដាក់សំលេង រឺរូបភាពលោកយាយ
នៅក្នុងវេបសាយ ដើម្បីអោយកូនចៅ ជំនាន់ក្រោយអោយដឹង តើលោកយាយអនុញ្ញាតិទេ

ខៈអត់ចេះថាម៉េចផង
កៈចាស ជាចុងក្រោយហ្នឹង លោកយាយអាចអនុញ្ញាតិអោយគេដាក់អ្ហេលោកយាយ?

ខៈដាក់ចុះកូន ដាក់ចុះ៕